ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ដំណាំឪឡឹកសាច់លឿង
# WATER MELON CULTIVATION




រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**


ខែសីហា ឆ្នាំ២០២៣


023 220 811
023 220 810
012 881 995

#9-13, Street 7, Chaktomuk, Daun Penh, Phnom Penh | info@ardb.com.kh | www.ardb.com.kh

**មាតិកា**


១-សេចក្តីផ្តើម.......................................................................................................... ១

២-ការអនុវត្តការដាំដុះ.................................................................................................. ១

ក-ការរៀបចំដី.......................................................................................................... ១

ខ-ការរៀបចំប្រព័ន្ធទឹក............................................................................................... ១

គ-ការជ្រើសរើសពូជ.................................................................................................. ១

ឃ-រដូវកាលដាំដុះ..................................................................................................... ២

ង-វិធីដាំដុះ............................................................................................................. ២

ច-ការថែទាំ............................................................................................................. ២

ឆ-ការដាក់ជី........................................................................................................... ២

ជ-កត្តាចង្រៃ........................................................................................................... ២

ឈ-អាយុកាលដាំដុះ និងប្រមូលផល............................................................................. ២

ញ-និន្នាកាតម្លៃ....................................................................................................... ៣

៣-តម្រូវការទុនដំបូងក្នុងការដាំដុះដំណាំ “ឪឡឹកសាច់លឿង” សម្រាប់ផ្ទៃដីទំហំ ១ ហិកតា............ ៣

៤-ការវិភាគសេដ្ឋកិច្ចលើការដាំឪឡឹកសាច់លឿងលើផ្ទៃដីទំហំ១ហិកតា ដាំ៣វដ្តក្នុងមួយឆ្នាំ............ ៣

៥-លទ្ធភាពចំណេញផ្អែកលើនិន្នាកាតម្លៃ លើផ្ទៃដីទំហំ ១ ហិកតា.............................................. ៤

៦-ខ្សែច្រវាក់តម្លៃ....................................................................................................... ៥

៧-ហានិភ័យ.............................................................................................................. ៥

៨-សេចក្តីសន្និដ្ឋាន..................................................................................................... ៦

# ដំណាំឪឡឹកសាច់លឿង

## ១-សេចក្តីផ្តើម

ឪឡឹកសាច់លឿងជាប្រភេទបន្លែយកផ្លែ ដែលអាចបរិភោគផ្លែនៅខ្ចីធ្វើជាបន្លែសម្រាប់ស្ល និងផ្លែទុំដែលផ្តល់នូវអត្ថប្រយោជន៍ជាច្រើនចំពោះសុខភាពអ្នកបរិភោគ។ ដំណាំឪឡឹកសាច់លឿងដែលកសិករកម្ពុជានិយមដាំគឺប្រើគ្រាប់ពូជនាំចូលពីក្រៅប្រទេស។ បច្ចុប្បន្នឪឡឹកត្រូវបានបង្កាត់ចេញជាពូជច្រើនប្រភេទដូចជា ផ្លែឪឡឹកសម្បកពណ៌បៃតងចាស់សាច់ក្រហម ឪឡឹកសម្បកពណ៌បៃតងចាស់សាច់លឿង និងផ្លែឪឡឹកសំបកពណ៌លឿងសាច់ក្រហម។ បច្ចុប្បន្នឪឡឹកសាច់លឿងទទួលបានការគាំទ្រ និងមានតម្លៃល្អជាងឪឡឹកសាច់ក្រហម។

## ២-ការអនុវត្តការដាំដុះ

**ក. ការរៀបចំដី÷**-ភ្ជួរដីឱ្យម៉ដ្ឋល្អពី២ ទៅ៣សារ រួចហាលដីទុករយៈពេលពី ១០ ទៅ ១៥ថ្ងៃ។ ធ្វូតជារងដែលមានទទឹងរងពី ១ម៉ែត្រ ប្រើប្រាស់ជីធម្មជាតិទ្រាប់បាតក្នុងបរិមាណ៤តោន/ហិកតា តាមរងដំណាំ ដោយទុកចន្លោះពីរងមួយទៅរងមួយប្រវែង៣ម៉ែត្រ។ នៅរដូវប្រាំងគួរប្រើប្រាស់គម្របសរីរាង្គលើរងដើម្បីកាត់បន្ថយចំណាយថ្លៃដើម និងកម្តៅ ឯរដូវវស្សាគួរជ្រើសរើសគម្របផ្លាស្ទិកដើម្បីកាត់បន្ថយស្មៅចង្រៃ ការជាំទឹក និងរក្សាសំណើម។

**ខ. ការរៀបចំប្រព័ន្ធទឹក ÷**ប្រើប្រាស់ប្រព័ន្ធដំណក់ទឹកទ្រីប គឺសមស្របសម្រាប់ដំណាំឪឡឹក។

**គ. ការជ្រើសរើសពូជ÷**ពូជមួយចំនួនដែលកសិករជ្រើសរើសសម្រាប់ការដាំដុះ




ពូជ Watermelon WAT-2710




ពូជ Watermelon WAT-2789




ពូជ 169

-ពូជ Watermelon WAT-2710 និងពូជ Watermelon WAT-2789 នាំចូលពីចិនតៃវ៉ាន់ ផលិតដោយក្រុមហ៊ុន KNOWN-YOU

-ពូជ169 នាំចូលពីប្រទេសថៃ ផលិតដោយក្រុមហ៊ុន Advance

**ឃ.រដូវកាលដាំដុះ÷** ដំណាំឪឡឹកសាច់លឿងអាចដាំបានគ្រប់រដូវ ប៉ុន្តែដោយសារកសិករភាគច្រើនដាំនៅលើទីវាលគួរដាំដុះចាប់ពីខែវិច្ឆិកា រហូតដល់ខែឧសភា។ ការដាំឪឡឹកលឿងដែលអាចទទួលបានទិន្នផលខ្ពស់ គួរដាំចន្លោះពីខែមករា រហូតដល់ខែឧសភា ដោយសារខែនេះមិនសូវមានភ្លៀងធ្លាក់ ដែលធ្វើឱ្យដំណាំឪឡឹកមិនសូវមានជំងឺ និងរលួយផ្លែ។

**ង.វិធីដាំដុះ÷** ត្រូវយកកូនឪឡឹកដែលមានអាយុពី៧-១០ថ្ងៃ ក្នុងថាសបណ្តុះមកដាំលើរងដែលបានលើករួចរាល់ ដោយដាំក្នុងចន្លោះគុម្ព ៥០ស.ម ចំណែកចន្លោះរងគឺទុកសម្រាប់ឱ្យដើមឪឡឹកលូតលាស់។

**ច.ការថែទាំ÷** ត្រូវស្រោចទឹកក្នុងមួយថ្ងៃ២ដង គឺនៅពេលព្រឹកម្តង និងពេលរសៀលម្តង ផ្អែកលើសំណើមដីដោយប្រើប្រាស់ប្រព័ន្ធដំណក់ទឹក។ បន្ទាប់ពីដាំបានរយៈពេល៣ថ្ងៃឡើងទៅត្រូវមានកាលវិភាគប្រើប្រាស់ថ្នាំជីវសាស្ត្រ និងថ្នាំពុលកសិកម្ម បង្ការជំងឺ និងសត្វល្អិត សម្រាប់ការពារករណីដែលអាចកើតមានកត្តាចង្រៃបំផ្លាញដំណាំ ។

**ឆ.ការដាក់ជី÷** ក្រោយការដាំដុះរួចរាល់ត្រូវមានកម្មវិធីប្រើប្រាស់ជីសម្រាប់ឪឡឹកសាច់លឿង។ កសិករអាចប្រើប្រាស់ប្រភេទជីទឹក នៅដំណាក់កាលលូតលាស់ ដោយបញ្ចូលតាមប្រព័ន្ធដំណក់ទឹក និងការបាញ់បន្ថែមទៅលើស្លឹក។

**ជ.កត្តាចង្រៃ÷** ជាទូទៅកសិករតែងជួបប្រទះជាញឹកញាប់នូវកត្តាចង្រៃដែលបំផ្លាញដំណាំឪឡឹកមានដូចជា ÷ អណ្តើកមាស រុយស ពីងពាងក្រហម ដង្កូវស៊ីញ៉ែ ទ្រីព និងជំងឺផ្សិតជាដើម។



**ឈ.អាយុកាលដាំដុះ និងប្រមូលផល÷** អាយុកាលបណ្តុះកូន ប្រើប្រាស់ពេលពី៧ ទៅ ១០ថ្ងៃ ចាប់ពីពេលដាក់ដាំកូនរហូតដល់ចេញផ្កាមានរយៈពេល២៥-៣០ថ្ងៃ។ កសិករអាចប្រមូលផលផ្លែឪឡឹកសាច់លឿងបានបន្ទាប់ពីដាំបានអាយុពី៥៥-៦០ថ្ងៃ (ចាប់ពីដាក់គ្រាប់រហូតបានប្រមូលផល រយៈពេលពី

៦០-៧០ថ្ងៃ)។ រសជាតិផ្អែមរបស់ឪឡឹកសាច់លឿង នឹងប្រែប្រួលក្នុងរយៈពេល១សប្តាហ៍ ក្រោយពេលទុំ ដូច្នេះត្រូវតែប្រាកដថាការប្រមូលផលត្រឹមត្រូវតាមពេលវេលាជាក់លាក់។ ត្រូវមានឧបករណ៍រក្សាទុកឪឡឹកទុំពេលដឹកជញ្ជូនដើម្បីការពារឪឡឹកពីការជាំ ឬបែក។

**៧. និន្នាកាតម្លៃ÷** ឪឡឹកគ្រប់ប្រភេទគឺងាយស្រួលដាំដុះចាប់ពីរដូវរំហើយ ក្នុងខែវិច្ឆិកា ដល់ខែឧសភា។ ឪឡឹកទទួលបានតម្លៃសមរម្យនៅរដូវវស្សាដោយសារពិបាកក្នុងការដាំដុះ។

**៣-តម្រូវការទុនដំបូងក្នុងការដាំដុះដំណាំ ឪឡឹកសាច់លឿង** (លើផ្ទៃដីទំហំ ១ហិកតា)

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---|
| ចំណាយលើការដាំដុះ | 17,880,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 29,800,000 |
| **សរុប** | 47,680,000 |

**៤-ការវិភាគសេដ្ឋកិច្ចលើការដាំឪឡឹកសាច់លឿង** ( លើផ្ទៃដីទំហំ ១ហិកតា )

រយៈពេលដាំដុះ ៦០-៧០ថ្ងៃ / វដ្ត (ការដាំដុះនៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ)

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ/ឯកត្តា (រៀល) | ទឹកប្រាក់ (រៀល) | ចំនួនសារវិលស់ | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលពីការលក់** | គ.ក | 25,000 | 2,000 | 50,000,000 | | **50,000,000** |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល** | | | | | | **21,466,667** |
| **២.ក-ចំណាយប្រែប្រួលសរុប** | | | | | | **17,880,000** |
| ភ្ជួរដី | សារ | 3 | 300,000 | 900,000 | | 900,000 |
| ពូជ | កញ្ចប់ | 20 | 80,000 | 1,600,000 | | 1,600,000 |
| ពលកម្ម | នាក់/ដង | 32 | 30,000 | 960,000 | | 960,000 |
| ជីធម្មជាតិសញ្ញាផែនដី | បាវ | 80 | 110,000 | 8,800,000 | | 8,800,000 |
| ជីទឹក ប៉ប៉ន | វដ្ត | 1 | 500,000 | 500,000 | | 500,000 |
| ជី កាល់ប្ញូរ៉ន | កញ្ចប់ | 10 | 35,000 | 350,000 | | 350,000 |
| ថ្នាំសត្វល្អិត និងជំងឺ | វដ្ត | 1 | 2,000,000 | 2,000,000 | | 2,000,000 |

| | | | | | | |
|---|---|---|---|---|---|---|
| ឈ្នួលបាញ់ថ្នាំ | ថ្ងៃ/ដង | 20 | 50,000 | 1,000,000 | | 1,000,000 |
| ជីបណ្តុះ(៤០គ.ក) | ការ៉ុង | 3 | 240,000 | 720,000 | | 720,000 |
| អន្ទាក់ស្អិត | សន្លឹក | 400 | 2,000 | 800,000 | | 800,000 |
| ថាសបណ្តុះ | កេះ | 1 | 250,000 | 250,000 | | 250,000 |
| **២.ខ-ចំណាយមិនប្រែប្រួលសរុប** | | | | | | **3,586,667** |
| សូឡាបូមទឹក(៥ឆ្នាំ) | គ្រឿង | 1 | 20,000,000 | 20,000,000 | 15 | 1,333,333 |
| ទុយោមេ (៥ឆ្នាំ) | ម៉ែត្រ | 100 | 24,000 | 2,400,000 | 15 | 160,000 |
| ទុយោចែកចាយ (៥ឆ្នាំ) | ម៉ែត្រ | 100 | 14,000 | 1,400,000 | 15 | 93,333 |
| ប្រព័ន្ធដំណក់ទឹក(១ឆ្នាំ) | ឈុត | 1 | 6,000,000 | 6,000,000 | 3 | 2,000,000 |
| **៣-ចំណេញសរុប** | | | | | | **28,533,333** |
| **ថ្លៃដើម/គ.ក** | | | | | | 858.67 |
| **ចំណេញ/គ.ក** | | | | | | 1,141.33 |

## ៥-លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃ លើផ្ទៃដីទំហំ ១ហិកតា៖

-តម្លៃទាបបំផុត ១,៨០០៛/គ.ក និងតម្លៃខ្ពស់បំផុត ២,៥០០៛/គ.ក

| ទិន្នផល គ.ក | តម្លៃ រៀល/គ.ក | ចំណូល រៀល | ចំណាយ រៀល | ចំណេញ-ខាត | |
|---|---|---|---|---|---|
| | | | | រៀល | % |
| 25,000 | 1,800 | 45,000,000 | 21,466,667 | 23,533,333 | 110% |
| 25,000 | 1,900 | 47,500,000 | 21,466,667 | 26,033,333 | 121% |
| 25,000 | 2,000 | 50,000,000 | 21,466,667 | 28,533,333 | 133% |
| 25,000 | 2,100 | 52,500,000 | 21,466,667 | 31,033,333 | 145% |
| 25,000 | 2,200 | 55,000,000 | 21,466,667 | 33,533,333 | 156% |
| 25,000 | 2,300 | 57,500,000 | 21,466,667 | 36,033,333 | 168% |
| 25,000 | 2,400 | 60,000,000 | 21,466,667 | 38,533,333 | 179% |
| 25,000 | 2,500 | 62,500,000 | 21,466,667 | 41,033,333 | 191% |

### ៦-ខ្សែច្រវាក់តម្លៃ÷

**កសិករ÷** លក់២,០០០៛/គ.ក - ថ្លៃដើម៨៥៨៛/គ.ក = ចំណេញ ១,១៤២៛/គ.ក

**ឈ្មួញកណ្តាល÷** បោះដុំ ៣,០០០៛/គ.ក(ថ្លៃដឹកជញ្ជូន ៥០០៛/គ.ក) ចំណេញ ៥០០៛/គ.ក

**អ្នកលក់រាយ÷** លក់៤,០០០៛/គ.ក(ជួលតូប និងខូចខាត៥០០៛/គ.ក) ចំណេញ ៥០០៛/គ.ក

### ៧-ហានិភ័យ ÷

តាមរយៈនៃការចុះសិក្សាផ្ទាល់ពីកសិករដាំឪឡឹកសាច់លឿងនៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ មានហានិភ័យមួយចំនួនអាចកើតឡើងជាយថាហេតុលើដំណើរការដាំដុះ ដូចជា÷

| ល.រ | ប្រភេទហានិភ័យ | ពិពណ៌នាហានិភ័យ | វិធានការ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | ទិន្នផលធ្លាក់ចុះ បណ្តាលមកពីកត្តា<br>-សត្វល្អិត និងជំងឺផ្សិត<br>-ការប្រមូលផលមិនទាន់ពេល<br>-ភ្លៀងធ្លាក់ច្រើន | -គួរប្រើប្រាស់វិធានការការពារដំណាំ និងមានកាលវិភាគប្រើប្រាស់ថ្នាំត្រឹមត្រូវសម្រាប់សត្វល្អិត និងជំងឺ<br>-ត្រួតពិនិត្យឪឡឹកជារៀងរាល់ថ្ងៃនៅថ្ងៃប្រមូលផល ព្រោះអាចបណ្តាលឱ្យខូចគុណភាព និងរស់ជាតិ។<br>-រដូវវស្សាគួរដាំដុះនៅក្នុងផ្ទះសំណាញ់ ប៉ុន្តែត្រូវធ្វើឱ្យមានដំណើរលំអង តាមរយៈការបេះផ្កាឈ្មោលទៅប៉ះផ្កាញី ឬប្រើប្រាស់កង្ហារ |
| ២ | ហានិភ័យទីផ្សារ | ពីខែវិច្ឆិកា ដល់ ឧសភា មានការប្រកួតប្រជែងតម្លៃ ដោយសារអាកាសធាតុអំណោយផល | -ពង្រីកបណ្តាញទីផ្សារឱ្យបានច្រើន ដើម្បីកាត់បន្ថយការពឹងផ្អែកលើទីផ្សារតែក្នុងតំបន់<br>-ចងក្រងក្រុមផលិត ដើម្បីធ្វើកិច្ចសន្យា ទិញ-លក់ និងធ្វើផែនការផលិតតាមកិច្ចសន្យា<br>-ផលិតឱ្យបានទាំងបរិមាណ និងគុណភាព<br>-ធ្វើការស្រាវជ្រាវព័ត៌មានទីផ្សារជាប្រចាំ |

## ៨-សេចក្តីសន្និដ្ឋាន

ឪឡឹកសាច់លឿងគឺជាដំណាំងាយស្រួលថែទាំ មានអាយុកាលខ្លី មិនសូវខ្វះទីផ្សារនោះទេ ព្រោះមានឈ្មួញមកទទួលទិញដល់ចម្ការ ដើម្បីលក់ចែកចាយទៅទីផ្សារក្នុងស្រុក និងនៅផ្សារទំនើបក្នុងទីក្រុងភ្នំពេញ ដោយលក់ក្នុងតម្លៃបោះដុំ១,៨០០-២,០០០៛/គ.ក ជាតម្លៃដែលកសិករមានលទ្ធភាពចំណេញ ហើយម្យ៉ាងទៀតតម្លៃឪឡឹកសាច់លឿងមិនសូវប្រែប្រួលខ្លាំងដូចដំណាំបន្លែផ្សេងៗទៀតទេ ហើយថែមទាំងមានការពេញនិយមពីសំណាក់អ្នកបរិភោគទៀតផង។

**ប្រភពនៃការសិក្សាស្រាវជ្រាវ៖**

-កសិករដាំដុះឪឡឹកសាច់លឿងស្ថិតនៅឃុំភ្នំតូច នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ

-ឯកសារបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ